# ភាពជោគជ័យនៃសមាគមសន្សំប្រាក់គ្រូបង្រៀននៅវិទ្យាល័យបាភ្នំ (ខេត្តព្រៃវែង)

ក្រោយពីបានចូលរួមក្នុងវេទិកាគ្រូបង្រៀន ដែលរៀបចំឡើងដោយអង្គការ សេដាក សហការជាមួយមូលនិធិ ហ្វ្រីឌ្រិច-ណៅម៉ាន់ នៃប្រទេសអាល្លឺម៉ង់ នៅឆ្នាំ ២០០៥ និងដើមឆ្នាំ ២០០៦ រួចមកលោកនាយក និងលោក គ្រូ-អ្នកគ្រូ បានផ្តួចផ្តើមគំនិតរៀបចំជា**សមាគមសន្សំប្រាក់គ្រូបង្រៀន**មួយប្រចាំវិទ្យាល័យ ។

លោកគ្រូ-អ្នកគ្រូចំនួនប្រមាណ ៥០ នាក់បានឯកភាពលើគំនិតនៃការបង្កើតក្រុមសន្សំប្រាក់នេះ ។

គោលបំណងនៃការចងក្រងជាសមាគមសន្សំប្រាក់គ្រូបង្រៀននេះគឺ:

១- ចូលរួមចំណែកលើកកំពស់ជីវភាពរបស់គ្រូបង្រៀន

២- ពង្រឹង និងពង្រីកចំណងសាមគ្គីភាពក្នុងចំណោមគ្រូបង្រៀនទាំងអស់

៣- ពង្រឹងនិយ័តភាពគ្រូបង្រៀនក្នុងការបំពេញការងារ ។

សមាគមត្រូវបានបង្កើតឡើងនៅខែ ឧសភា ឆ្នាំ ២០០៦ ដែលការចាប់ផ្តើមដំបូងមានសមាជិកចំនួន ៥១ នាក់ ក្នុងចំណោមគ្រូសរុប ១០៥ នាក់ចូលរួម ។

បច្ចុប្បន្នក្រោមគំនិតផ្តួចផ្តើមរបស់លោក វ៉ា សារុន នាយកវិទ្យាល័យបាភ្នំ សមាគមសន្សំប្រាក់អន្តរសាលាមួយត្រូវបានចងក្រងឡើងកាលពីខែ មេសា ឆ្នាំ ២០០៨ កន្លងមក ដោយមានលោកគ្រូ-អ្នកគ្រូ ចំនួន ១១៥ នាក់ មកពីគ្រប់សាលាក្នុងស្រុកបាភ្នំជាសមាជិក ។ សមាគមមានភាគហ៊ុនសរុបចំនួន ១២៦ ភាគហ៊ុន ដែលស្មើនឹង ១,២ លានរៀលក្នុងមួយខែៗ ហើយមកដល់ពេលនេះ សមាគមមានទុនចំនួន ១៧ លានរៀល ។ បច្ចុប្បន្ន នៅក្នុងស្រុកបាភ្នំ មានសមាគមសន្សំប្រាក់ចំនួន ១០ នៅក្នុង ១០ សាលា និងសមាគមអន្តរសាលាមួយ ដែលមានសមាជិកសរុបចំនួន ៤០៩ នាក់ មានភាគហ៊ុនចំនួន ៥៣២ ស្មើនឹង ៥ លានរៀលក្នុង ១ ខែៗ ។

ក្នុងចំណោមគ្រូបង្រៀនសរុប ៨០០ នាក់នៅទូទាំងស្រុកមានគ្រូបង្រៀនចំនួនប្រមាណ ៥០% (៤០៩ នាក់) ជាសមាជិកសមាគមសន្សំប្រាក់គ្រូបង្រៀន ។ សំរាប់លោកនាយក វ៉ា សារុន លោកចង់ឃើញគ្រូៗទាំងអស់ នៅគ្រប់សាលានៅទូទាំងប្រទេសកម្ពុជា រួបរួមគ្នាចងក្រងជាក្រុមសន្សំប្រាក់គ្រូបង្រៀននៅគ្រប់សាលា និង អាចឈានទៅបង្កើតជា " ធនាគារគ្រូបង្រៀន " នាពេលអនាគត ។ លោកនាយក វ៉ា សារុន បានចូលរួម យ៉ាងសកម្មក្នុងការងារផ្សព្វផ្សាយ និងចែករំលែកបទពិសោធន៍ដ៏ល្អនៅវិទ្យាល័យរបស់គាត់ ដល់សាលាផ្សេងៗទៀត តាមរយៈកម្មវិធីសំវាទដើម្បីអភិវឌ្ឍន៍ និងវេទិកាគ្រូបង្រៀននៅខេត្តចំនួន ៩ (ព្រៃវែង តាកែវ កំពង់ចាម ស្វាយរៀង កំពង់ឆ្នាំង កំពង់ធំ ពោធិសាត់ កំពត និងសៀមរាប) និងរាជធានីភ្នំពេញ ។